## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ២៧៧ អនក្រ.តត

# អនុក្រឹត្យ

# ស្តីពី

# ការតែងតាំងសមាជិកនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការបញ្ចូលសមាសភាព ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៦៨អនក្រ.បក ចុះថ្ងៃទី១៨ខែតុលា ឆ្នាំ២០០៤ ស្តីពីការកែប្រែមាត្រា ៤ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- អនុក្រឹត្យលេខ ៣៥ អនកក្រ.បក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែប្រែមាត្រា ៤ថ្មី នៃ អនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១៨ខែតុលា ឆ្នាំ២០០៤ ស្តីពីការកែប្រែមាត្រា ៤ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

# សម្រេច

**មាត្រា១.**

ត្រូវបានតែងតាំងសមាសភាពនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| - ឯកឧត្តម **អ៊ឹម ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបណីយកម្មនិងសំណង់ | ប្រធាន |
| - ឯកឧត្តម **ឱម យ៉ិនទៀង** | ទេសរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| - ឯកឧត្តម **ច័ន្ទ សារុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| - ឯកឧត្តម **សំ សុផល** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ និងជារដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| - ឯកឧត្តម **ទុំ ម៉េង** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| - ឯកឧត្តម **រ័ត្ន សារីន** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបណីយកម្មនិងសំណង់ និង ជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី | សមាជិកអចិន្ត្រៃយ៍ |
| - ឯកឧត្តម **នេព នន្ទរី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - ឯកឧត្តម **ប៉ុល លឹម** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| - ឯកឧត្តម **ម៉ឹង សំផន** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| - ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - ឯកឧត្តម **ឱក ប៊ុង** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| - ឯកឧត្តម **តាន់ តីមទន់** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្មតរ៉ែ និងថាមពល | សមាជិក |
| - ឯកឧត្តម **អ៊ុន សារឿង** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| - ឯកឧត្តម **ឌីក ត្រឿនទុត្តា** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| - ឯកឧត្តម **តន់ វ៉ាន់ថារ៉ា** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| - ឯកឧត្តម **លាវ ស៊ីណារ៉ា** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| - ឯកឧត្តម **ម៉ៅ សុវណ្ណា** | រដ្ឋលេខាធិការក្រសួងយុត្តិធ៌ម | សមាជិក |
| - ឯកឧត្តម **នូ សុវត្ថិ** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - ឯកឧត្តម **ឃឹម សារិទ្ធ** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| - ឯកឧត្តម **តោស៊ុំ សារឿត** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| - លោកជំទាវ **ខេង សំវ៉ាដា** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| - ឯកឧត្តម **អ៊ុន វីរៈជាត** | សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជារដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - ឯកឧត្តម **ស្ងួន សិទ្ធី** | អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

**មាត្រា២.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងសមាជិកទាំងអស់នៃ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានសមាសភាពចែងក្នុងមាត្រា ១ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ